**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០៣ . អនក្រ . បក

# អនុក្រឹត្យ

# ស្តីពី

# ការកាត់ដីទំហំសរុប ២.៣៩៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ១.១៣៧ ហិកតា និងពីព្រៃសម្បទានក្រុមហ៊ុន សំរោងវូឌ ទំហំ ១.២៦១ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.១៧៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង លើផ្ទៃដី ទំហំ ២.៣៦២ ហិកតា និងទំហំ ៣៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨អនក្រ.បកចុះថ្ងៃទី០៧ខែតុលាឆ្នាំ២០០៥ស្តីពីការគ្រប់គ្រង ដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដី សេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិង នីតិ វិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញសារាចរលេខ០២សរចុះថ្ងៃទី២៦ខែកុម្ភៈឆ្នាំ២០០៧ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ៨០៥ អបខ ចុះថ្ងៃទី២៣ខែ តុលា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១.-**

ត្រូវបានកាត់ទំហំសរុប ២.៣៩៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ១.១៣៧ ហិកតា និងពីព្រៃសម្បទានក្រុមហ៊ុន សំរោងវូឌ ទំហំ ១.២៦១ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង លើផ្ទៃដីទំហំ **២.៣៦២ ហិកតា** និងទំហំ **៣៦ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប នៅក្នុងភូមិ ឃុំដូចខាងក្រោម៖

- ផ្ទៃដីទំហំ ១.២៦១ហិកតា កាត់ចេញពីព្រៃសម្បទានសំរោងវូឌ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិខ្នារង្វាស ឃុំឃុនរាម តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ។
- ផ្ទៃដីទំហំ **១.១៣៧ ហិកតា** កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នូវផ្ទៃដីទំហំ **១.១០១ ហិកតា** និងរក្សាទុកជាដីសាធារណៈ ទំហំ **១១ ហិកតា** ព្រមទាំងរក្សាទុកសម្រាប់សហគមន៍ព្រៃឈើ ទំហំ **២៥ ហិកតា** នៅភូមិ ត្បែងលិច ឃុំត្បែង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅស្រុកបន្ទាយស្រី ខេត្តសៀមរាបដែលស្ថិតក្នុងភូមិ ឃុំដូចខាងក្រោម៖

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន **៧៣៧** គ្រួសារ នៅភូមិខ្នារង្វាស ឃុំឃុនរាម
- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន **៤៩១** គ្រួសារ នៅភូមិត្បែងលិច ឃុំត្បែង

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៤៣៣ អនក្រ.បក ចុះថ្ងៃទី..០៣..ខែ..វិច្ឆិកា..ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំសរុប ២.៣៩៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ១.១៣៧ ហិកតា និងពីព្រៃសម្បទានក្រុមហ៊ុនសំរោងវូដ ទំហំ១.២៦១ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ១.១៧៨ គ្រួសារ ទំហំ២.៣៦២ ហិកតា និងដីទំហំ ៣៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប




តារាងនិយាមការ

វាស់វែងដោយឧបករណ៍ GPS MAP 62s — Projection UTM Zone 48N ,Datum WGS84

| ID | E | N | ID | E | N | ID | E | N | ID | E | N |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 395637 | 1513648 | 16 | 402024 | 1516164 | 31 | 400760 | 1515723 | 46 | 397383 | 1515264 |
| 2 | 395667 | 1513767 | 17 | 402458 | 1516160 | 32 | 400638 | 1515706 | 47 | 396692 | 1515322 |
| 3 | 395873 | 1514196 | 18 | 402499 | 1516013 | 33 | 400505 | 1515716 | 48 | 395876 | 1513637 |
| 4 | 396136 | 1514713 | 19 | 402021 | 1516033 | 34 | 400465 | 1515619 | 49 | 402047 | 1516500 |
| 5 | 396344 | 1515099 | 20 | 401543 | 1516040 | 35 | 400362 | 1515139 | 50 | 402138 | 1516475 |
| 6 | 396736 | 1515807 | 21 | 401487 | 1516039 | 36 | 400324 | 1515085 | 51 | 402192 | 1516649 |
| 7 | 396902 | 1517299 | 22 | 401267 | 1516034 | 37 | 400052 | 1515076 | 52 | 402094 | 1516671 |
| 8 | 397097 | 1517340 | 23 | 401291 | 1515946 | 38 | 399967 | 1515087 | 53 | 402242 | 1518215 |
| 9 | 397502 | 1517397 | 24 | 401260 | 1515650 | 39 | 399286 | 1515142 | 54 | 402253 | 1518199 |
| 10 | 397459 | 1517938 | 25 | 401300 | 1515460 | 40 | 399041 | 1515150 | 55 | 402297 | 1518202 |
| 11 | 397585 | 1518295 | 26 | 401282 | 1515406 | 41 | 398876 | 1515346 | 56 | 402307 | 1518178 |
| 12 | 400741 | 1518291 | 27 | 401146 | 1515479 | 42 | 398370 | 1515329 | 57 | 402370 | 1518172 |
| 13 | 400797 | 1517485 | 28 | 400997 | 1515607 | 43 | 398278 | 1515286 | 58 | 402369 | 1518239 |
| 14 | 400840 | 1516395 | 29 | 401001 | 1515704 | 44 | 397609 | 1515247 | 59 | 402272 | 1518260 |
| 15 | 402019 | 1516276 | 30 | 400854 | 1515721 | 45 | 397503 | 1515256 | 60 | 402271 | 1518213 |

# ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី..១៨..ខែ..វិច្ឆិកា..ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំសរុប ២.៣៩៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ១.១៣៧ ហិកតា និងពីព្រៃសម្បទានក្រុមហ៊ុនសំរោងវូឌ ទំហំ១.២៦១ ហិកតា និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងជាំផ្ទះជាក់ស្តែងចំនួន ១.១៧៨ គ្រួសារ ទំហំ២.៣៦២ ហិកតា និងដីទំហំ ៣៦ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប




**តារាងទិយាមកា**
**វាស់វែងដោយឧបករណ៍ GPS MAP 62s**
Projection UTM Zone 48N.Datum WGS84

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 396007 | 1503760 | 38 | 394244 | 1497209 |
| 2 | 396308 | 1503436 | 39 | 394212 | 1497080 |
| 3 | 396205 | 1503270 | 40 | 394170 | 1496897 |
| 4 | 396118 | 1503314 | 41 | 394185 | 1496815 |
| 5 | 395997 | 1503418 | 42 | 394408 | 1496858 |
| 6 | 395975 | 1503384 | 43 | 394351 | 1496720 |
| 7 | 395931 | 1503427 | 44 | 394561 | 1496739 |
| 8 | 395899 | 1503509 | 45 | 395041 | 1496855 |
| 9 | 394064 | 1502619 | 46 | 395142 | 1496778 |
| 10 | 393765 | 1502433 | 47 | 395300 | 1496924 |
| 11 | 393486 | 1502098 | 48 | 395407 | 1497039 |
| 12 | 393300 | 1501983 | 49 | 395811 | 1497567 |
| 13 | 393670 | 1501893 | 50 | 396007 | 1497849 |
| 14 | 393660 | 1501692 | 51 | 396627 | 1498953 |
| 15 | 393693 | 1501382 | 52 | 396698 | 1499087 |
| 16 | 393785 | 1501369 | 53 | 397043 | 1499738 |
| 17 | 394366 | 1501130 | 54 | 397186 | 1500044 |
| 18 | 394527 | 1501090 | 55 | 397311 | 1500029 |
| 19 | 394588 | 1501103 | 56 | 397303 | 1500304 |
| 20 | 394774 | 1500884 | 57 | 397289 | 1500423 |
| 21 | 394860 | 1500704 | 58 | 397490 | 1500890 |
| 22 | 394971 | 1500394 | 59 | 397643 | 1501107 |
| 23 | 394918 | 1500056 | 60 | 397751 | 1501388 |
| 24 | 394449 | 1498978 | 61 | 397828 | 1501437 |
| 25 | 394348 | 1498728 | 62 | 397811 | 1501556 |
| 26 | 394341 | 1498678 | 63 | 397505 | 1502000 |
| 27 | 394344 | 1498628 | 64 | 397534 | 1502073 |
| 28 | 394355 | 1498567 | 65 | 397423 | 1502333 |
| 29 | 394403 | 1498389 | 66 | 397272 | 1502493 |
| 30 | 394415 | 1498279 | 67 | 396038 | 1500959 |
| 31 | 394394 | 1498052 | 68 | 395942 | 1501037 |
| 32 | 394372 | 1497961 | 69 | 395926 | 1501016 |
| 33 | 394353 | 1497833 | 70 | 395856 | 1501067 |
| 34 | 394308 | 1497678 | 71 | 395683 | 1500835 |
| 35 | 394305 | 1497648 | 72 | 395533 | 1500964 |
| 36 | 394306 | 1497468 | 73 | 394379 | 1502155 |
| 37 | 394301 | 1497313 | | | |